**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**គណៈកម្មការប្រឹក្សាការងារ**

# សេចក្តីថ្លែងការណ៍របស់គណៈកម្មការប្រឹក្សាការងារ

ឆ្នាំ២០១៤ ខែមិថុនា ថ្ងៃទី១៦ វេលាម៉ោង ៨:៣០ នាទីព្រឹក គណៈកម្មការប្រឹក្សាការងារបាន បើកកិច្ចប្រជុំការងារ លើកទី៧ អាណត្តិទី៨ នៅទីស្តីការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បី ពិនិត្យលើអនុសាសន៍ទាំង ៥ របស់សិក្ខាសាលាពិគ្រោះយោបល់ត្រីភាគីថ្នាក់ជាតិស្តីពី "ការពង្រឹងដំណើរការ នៃការកំណត់ប្រាក់ឈ្នួលអប្បបរមានៅប្រទេសកម្ពុជា" កាលពីថ្ងៃទី២៤-២៥ ខែមេសា ឆ្នាំ២០១៤ និងកម្មវិធី ការងារផ្សេងៗរបស់គណៈកម្មការប្រឹក្សាការងារ។ ក្រោយពីមានការពិគ្រោះយោបល់គ្នាយ៉ាងផុសផុល និងគ្រប់ ជ្រុងជ្រោយ គណៈកម្មការប្រឹក្សាការងារបានសម្រេចដូចខាងក្រោម៖

១-សម្រេចជាឯកច្ឆន្ទទទួលយកលទ្ធផលសិក្ខាសាលាពិគ្រោះយោបល់ត្រីភាគីថ្នាក់ជាតិ កាលពីថ្ងៃ ទី២៤-២៥ ខែមេសា ឆ្នាំ២០១៤ ក្រោមជំនួយបច្ចេកទេសរបស់អង្គការអន្តរជាតិខាងការងារ។

២-សម្រេចជាឯកច្ឆន្ទទទួលយកវិធីសាស្រ្ត នៃការអនុម័តសេចក្តីសម្រេចរបស់គណៈកម្មការប្រឹក្សា ការងារដោយយន្តការកុងសង់ស៊ុស។ ក្នុងករណីមិនមានកុងសង់ស៊ុសលើចំណុចណាមួយចំនួន ២ ដង ក្នុងកិច្ច ប្រជុំ ២ ផ្សេងគ្នានោះ ត្រូវអនុវត្តយកយន្តការសម្លេងភាគច្រើនតាមរយៈការបោះឆ្នោតដោយសម្ងាត់នាកិច្ចប្រជុំ លើកទី២នោះ។

៣-កំណត់យកដើមត្រីមាសទី៣ នៃឆ្នាំនីមួយៗ ជាការចាប់ផ្តើមពិភាក្សា និងសិក្សាស្រាវជ្រាវលើ ស្ថានភាពប្រាក់ឈ្នួលអប្បបរមា ដើម្បីលើកជាយោបល់ជូនកិច្ចប្រជុំពេញអង្គរបស់គណៈកម្មការប្រឹក្សាការងារ ពិនិត្យសម្រេចអនុម័តយ៉ាងយូរនៅចុងត្រីមាសទី៣ នៃឆ្នាំនោះ។ គណៈកម្មការប្រឹក្សាការងារនឹងបើកកិច្ចប្រជុំ នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៤ ខាងមុខបន្តទៀត ដើម្បីពិភាក្សាបញ្ហាប្រាក់ឈ្នួលអប្បបរមា។

៤-កំណត់យកដើមត្រីមាសទី៤ នៃឆ្នាំនីមួយៗ ដើម្បីចេញប្រកាសស្តីពីប្រាក់ឈ្នួលអប្បបរមាសម្រាប់ ឆ្នាំបន្ទាប់ដោយចាប់អនុវត្តចាប់ពីថ្ងៃទី០១ ខែមករា នៃឆ្នាំបន្ទាប់ ដើម្បីទុករយៈពេល ៣ខែ ជូនភាគីពាក់ព័ន្ធ ត្រៀមអនុវត្ត។

៥-សម្រេចជាឯកច្ឆន្ទប្រកាន់យកនូវទស្សនៈសាមគ្គីរួបរួម ការពារផលប្រយោជន៍រួម និងការជជែក ពិភាក្សាដោយន័យស្ថាបនា និងគោលការណ៍ឈ្នះ-ឈ្នះ។

*រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៤*

| | | |
|---|---|---|
| **ប្រធានគណៈកម្មការប្រឹក្សាការងារ** | **អនុប្រធានគណៈកម្មការ**<br>**ប្រឹក្សាការងារតាគីតំណាងនិយោជក** | **អនុប្រធានគណៈកម្មការ**<br>**ប្រឹក្សាការងារតាគីតំណាងកម្មករនិយោជិត** |
| បណ្ឌិត **អ៊ិត សំហេង** | ឧកញ៉ាបណ្ឌិត **ណាង សុធី** | **ជួន មុំថុល** |